ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៦
ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥
សាលក្រមលេខ ១០២ "ឆ"
ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០២០

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០២០
វេលាម៉ោង ១៤ និង០០ នាទី រសៀល ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៦ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៥ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] **សុផាន់ណារិទ្ធ** ភេទប្រុស អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted] **យ៉ឺន** (រ) ម្តាយឈ្មោះ [redacted] **យ៉ាន** (រ) ប្រពន្ធឈ្មោះ[redacted] **សុខា** មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា និងអំពើលួច** ប្រព្រឹត្តនៅភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] **តារា** ភេទប្រុស អាយុ ៥២ឆ្នាំ មុខរបរជំនួយការមេធាវីតាព្រហ្មប្រចាំខេត្តកំពង់ឆ្នាំង មានអាស័យដ្ឋានស្ថិតនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២២២៤ដ.ក.ស.ព/២០ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

បានឃើញ ដីកាដំណោះស្រាយលេខ ៧៨៨/២០ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង ។



Scanned with CamScanner

Scanned with CamScanner

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ

កាលពីថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ វេលាម៉ោង ០៧ និង០០ នាទី ព្រឹក នៅចំណុចភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានឈ្មោះ សារិន សុផាន់ណារិទ្ធ ភេទប្រុស រស់នៅភូមិ-ឃុំកើតហេតុខាងលើ បានទៅដកបង្គោលរបង រើបន្លាលួស កាប់គាស់ដើមចន្ទី នៅលើដីដែលនៅជាប់នឹងព្រំដីរបស់ឈ្មោះ [redacted] តារា ភេទប្រុស ដើម្បីសាងសង់របងស៊ីម៉ង់រៀបឥដ្ឋ ហើយត្រូវបានឈ្មោះ [redacted] តារា ប្តឹងទប់ស្កាត់ការសាងសង់នេះ ហើយបានប្តឹងទៅលើឈ្មោះ សារិន សុផាន់ណារិទ្ធ ថាបានដកយកបង្គោលរបង បន្លាលួស និងគាប់ដើមចន្ទីរបស់ខ្លួន ធ្វើឱ្យខូចខាតផលប្រយោជន៍អស់ជាច្រើន ដោយសារបង្គោលរបង និងបន្លាលួសនេះបានបាត់អស់ ។

## នាពេលសវនាការ

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារិទ្ធ បានឆ្លើយនៅចំពោះមុខតំណាងអយ្យការថា៖ ចំពោះដីនេះគឺខ្លួនបានទិញពីឈ្មោះ យូ សុផាន់ ភេទប្រុស ចំនួន ០៦ អា ៧២ សង់ទីអា ដែលមានប័ណ្ណសំគាល់អចលនវត្ថុលេខក.ឆ ០០០៩៨៧ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៦ ។ ចំពោះដីនេះដំបូងជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ជ្រា ភេទប្រុស ធ្វើការនៅភ្នំពេញដោយបានធ្វើរបងដាំដើមចន្ទីជាព្រំដី ហើយមានព្រំប្រទល់ជាប់នឹងឈ្មោះ [redacted] តារា ។ នៅពេលឈ្មោះ [redacted] តារា បានមកទិញដីគឺបានមកបោះបង្គោលស៊ីម៉ង់ចំនួន ០២ ដើម នៅជាប់ព្រំដីរបស់ខ្លួន ហើយទាំងបានដកបង្គោលក្រាក់ចាស់របស់ឈ្មោះ ប៊ុន ជ្រា ដែលគាត់បានធ្វើពីមុនទៀតផង ។ អំឡុងខែមករា ឆ្នាំ២០១៥ ខ្លួនបានរៀបចំធ្វើរបងថ្ម ដោយបានទូរសព្ទប្រាប់ឈ្មោះ ហែម តារា ដែរ តែរូបគេមិនបានមកមើលទេ ហើយខ្លួនក៏បានចាប់ផ្តើមធ្វើដោយកាប់ដើមចន្ទីចំនួន ០១ ដើម ដែលដុះក្នុងព្រំដីរបស់ខ្លួន ហើយពេលកាប់ដួលដើមចន្ទីនោះបានដួលលើដីរបស់ឈ្មោះ [redacted]តារា រីឯបង្គោលរបងខ្លួនបានដកចេញជាមួយនឹងបន្លាលួសចំនួន ០២ សសរ ។ លុះពេលខ្លួនធ្វើរបងឥដ្ឋបានចំនួនកន្លះ ម៉ែត្រ ស្រាប់តែឈ្មោះ [redacted] តារា បានមកហាមឃាត់មិនឱ្យធ្វើបន្តទៀត ហើយរូបគេក៏បានប្តឹងទៅសាលាក្រុងកំពង់ឆ្នាំង ពេលនោះខ្លួនក៏បានឈប់សាងសង់ ហើយបានដាក់ពាក្យស្នើសុំទៅសាលាក្រុង និងបានដោះស្រាយជាមួយឈ្មោះ [redacted] តារា ។ នៅពេលដោះស្រាយនោះឈ្មោះ [redacted] តារា មិនបានចូលមកទេ គឺឱ្យឈ្មោះ លីន ត្រូវជាកូនធម៌ចូលមកជំនួសដោយបានទាក់ទងជាមួយឈ្មោះ ហែម តារា តាមទូរសព្ទ ហើយឈ្មោះ ហែម តារា ក៏បានយល់ព្រមឱ្យខ្លួនធ្វើបន្តទៀតនិងបានរៀបចំឯកសារចាំរូបគេមកផ្តិតមេដៃតាមក្រោយ ហើយសាលាក្រុងក៏បានអនុញ្ញាតឱ្យខ្លួនសាងសង់រហូតរួចរាល់ជាស្ថាពរ។ ខ្លួនក៏មិនបានដឹងថាហេតុអីបានជាឈ្មោះ [redacted] តារា មកប្តឹងខ្លួនដែរ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តារា បានឆ្លើយថា ៖ នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ ឈ្មោះ [redacted]ណារិទ្ធិ នៅភូមិម៉ុងបារាំង បានមកកាប់គាស់របងគ្រាក់ និងបន្លាលួសយកទៅបាត់និងបានកាប់ស្វាយចន្ទីយកដីខ្លួន ។ គេខ្លួនសួរនាំគាត់បានប្រើប្រាស់ហឹង្សាមកលើខ្លួនទៀតដោយមាន

បក្សពួកគួកន។ ហើយខ្លួនបានដាក់ខលទៅសួរអភិបាលក្រុង គេថាមិនបានអនុញ្ញាតឱ្យសាងសង់ទេ ហើយខ្លួនបានដាក់ពាក្យសុំហាមឃាត់ តែដោយសារតែគាត់មានបក្សពួកនាំឱ្យគាត់បន្តរសាងសង់រហូតបានសម្រេច ។ ហើយខ្លួនបានដាក់ពាក្យប្តឹងមកអយ្យការ។ ខ្លួនបានបាត់បង្គោលក្រាក់អស់ចំនួន ១០០ ដើមបន្ទាល្អស ១០ ដុំ ក្នុងមួយដុំតម្លៃជាងដប់ដុល្លារ ស្វាយចន្ទីកាប់ចោលអស់ជាង២០ដើម ដែលកំពុងចេញផ្លែផ្កាហើយ។ សូមទាមទារទាំងសំណងនិងការខូចខាតចំនួន ១០០ លានរៀល។

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **សំណាង** បានឆ្លើយនៅចំពោះមុខអយ្យការថា៖ ខ្លួនមិនបានដឹងអ្វីនោះទេ ការដែលឈ្មោះ [redacted] សុផាន់ណារិទ្ធ ទៅធ្វើរបងនោះខ្លួនមិន បានទៅមើលនោះទេនៅថ្ងៃដែលសាលាក្រុងដឹកនាំកំលាំងចុះត្រួតពិនិត្យការសាងសង់ របងរបស់ឈ្មោះ [redacted] សុផាន់ណារិទ្ធ គឺខ្លួនគ្រាន់តែទៅមើលជាមួយគេ មិនបានចូលរួមដោះស្រាយជាមួយក្រុមការងារ ទេ ហើយខ្លួនក៏មិនដែលបានជួបជាមួយឈ្មោះ [redacted] តារា ដែរ តែគ្រាន់តែដឹងថាដីនោះគឺឈ្មោះ [redacted] សុផាន់ណារិទ្ធ បានធ្វើការផ្ទេរពីឈ្មោះ [redacted] សុផាន់ តែប៉ុណ្ណោះ ក្រៅពីនោះខ្លួនមិនបានដឹងនោះទេ ។

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **សំរាត** បានឆ្លើយនៅចំពោះមុខតំណាងអយ្យការថា ៖ កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៥ ខ្លួនបានទទួលបេសកម្មចុះត្រួតពិនិត្យលើដីទំនាស់រវាងឈ្មោះ [redacted] សុផាន់ណារិទ្ធ ជាមួយឈ្មោះ [redacted] តារា មានទីតាំងស្ថិតនៅភូមិម៉ុងបារាំងហើយខ្លួនក៏បានចូលរួមដែរ នៅថ្ងៃនោះឈ្មោះ [redacted] តារា មិនបានចូលមកទេហើយលោកអភិបាលក្រុងក៏បានធ្វើការណែនាំ និងហាមឃាត់ម្ចាស់សំណង់ មិនឲ្យធ្វើការបន្តទៀត និងបានឲ្យគាត់ស្នើសុំច្បាប់អនុញ្ញាត ។ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ លោក ហ៊ីង ភ័ក្ត្រមីនា បានចុះដោះស្រាយម្តងទៀត ហើយខ្លួនក៏បានចូលរួមដែរ តែឈ្មោះ [redacted] តារា មិនបានចូលរួមទេ តែបានជួបនិយាយតាមទូរស័ព្ទ ហើយបានយល់ព្រមឲ្យឈ្មោះ [redacted] សុផាន់ណារិទ្ធ ធ្វើការសុំទោសតាមទូរសព្ទទើបរូបគេយល់ព្រមឲ្យសាងសង់បន្តទៀត ដោយធ្វើកំណត់ហេតុរង់ចាំរូបគេមកផ្តិតមេដៃតាមក្រោយ ។ នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឈ្មោះ [redacted] តារា បានមកជួបខ្លួនដើម្បីផ្តិតមេដៃលើកំណត់ហេតុ ប៉ុន្តែរូបគេបានឲ្យខ្លួនធ្វើកំណត់ហេតុមួយទៀត ដោយឲ្យឈ្មោះ [redacted] សុផាន់ណារិទ្ធ ទទួលស្គាល់កំហុសថាបានដកបង្គោល និងកាប់បំផ្លាញដើមចន្ទីរបស់គេ តែឈ្មោះ [redacted] សុផាន់ណារិទ្ធ មិនយល់ព្រម ពេលនោះឈ្មោះ [redacted] តារា ក៏មិនព្រមផ្តិតមេដៃលើកំណត់ហេតុចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ នោះដែរ ។ ការដោះស្រាយនេះបានស្ងប់ស្ងាត់ទៅវិញមួយរយៈ ទើបលឺដំណឹងថាឈ្មោះ [redacted] សុផាន់ណារិទ្ធ បានធ្វើរបងរួចរាល់ជាស្ថាពរ ។

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **ភ័ក្ត្រមីនា** បានឆ្លើយនៅចំពោះមុខតំណាងអយ្យការថា ៖ កាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០១៥ មានឈ្មោះ [redacted] តារា បានដាក់ពាក្យប្តឹងចូលមកសាលាក្រុងកំពង់ឆ្នាំង សុំទប់ស្កាត់ការសាងសង់របងឈ្មោះ [redacted] សុផាន់ណារិទ្ធ

មានទីតាំងនៅភូមិម៉ុងបារាំង។ ហើយនៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៥ អភិបាលក្រុងបានចាត់ខ្លួនឱ្យមកដោះស្រាយលើបណ្តឹងនោះ ។ នៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៥ ខ្លួនបានចុះទៅកន្លែងពិនិត្យទីតាំងដីទំនាស់ដោយបានអញ្ជើញភាគីឈ្មោះ [redacted] តារា តាមរយៈឈ្មោះ លីន ត្រូវជាកូនធម៌ដើម្បីឱ្យទៅចូលរួម តែដល់ថ្ងៃកំណត់ឈ្មោះ [redacted]តារា មិនបានចូលមកទេ គឺមានតែឈ្មោះ [redacted] សុផាន់ណារិទ្ធ និងអាជ្ញាធរភូមិឃុំ នឹងរូបខ្លួនតែប៉ុណ្ណោះ ហើយឈ្មោះ [redacted] តារា បានណែនាំឱ្យឈប់សាងសង់សំណង់ជាបណ្តោះអាសន្នរង់ចាំការដោះស្រាយពេលក្រោយ។ នៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៥ ខ្លួនបានចេញលិខិតអញ្ជើញភាគីទាំងពីរ ឱ្យចូលដោះស្រាយនៅទីតាំងដីទំនាស់ ប៉ុន្តែនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ឈ្មោះ [redacted] តារា មិនបានចូលមកទេ គឺឱ្យឈ្មោះ សាលីម ជាអ្នកតំណាងហើយពេលដំណោះស្រាយខ្លួនបានទូរស័ព្ទជួបឈ្មោះ [redacted] តារា ផ្ទាល់ដើម្បីធ្វើការសម្របសម្រួលហើយឈ្មោះ [redacted] តារា ចង់ជួបជាមួយឈ្មោះ [redacted] សុផាន់ណារិទ្ធ ដើម្បីឱ្យសុំទោសរូបគេ ទើបរូបគេឱ្យសាងសង់បន្តទៀត ។ តែឈ្មោះ [redacted] តារា សុំឱ្យឈ្មោះ [redacted]សុផាន់ណារិទ្ធ បោះបង្គោលដែលបានដកនោះមកខាងដីរបស់គាត់ ហើយឈ្មោះ [redacted] តារា ក៏បានយល់ព្រមឱ្យសាងសង់បន្តលើគ្រឹះដែលឈ្មោះ [redacted] សុផាន់ណារិទ្ធ បានសាងសង់ ៥០% នោះរួចហើយ ប៉ុន្តែឈ្មោះ [redacted] តារា មិនព្រមផ្តិតមេដៃលើកំណត់ហេតុទេព្រោះរូបគេមិនបានចូលរួមផ្ទាល់ ហើយខ្លួនក៏បានណាត់មកឱ្យផ្តិតមេដៃនៅសាលាក្រុង ។ នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឈ្មោះ [redacted] តារា បានមកជួបជាមួយឈ្មោះ[redacted]សំអាត នៅសាលាក្រុងតែរូបគេមិនបានផ្តិតមេដៃនោះទេ ហើយបានណែនាំឱ្យខ្លួនធ្វើលិខិត ០១ ច្បាប់ ដោយដាក់ឱ្យឈ្មោះ [redacted] សុផាន់ណារិទ្ធ ទទួលស្គាល់កំហុសថាបានជីករបងរំលោភលើដីរបស់ខ្លួន និងបានកាប់បំផ្លាញដើមចន្ទី តែឈ្មោះ [redacted] សុផាន់ណារិទ្ធ មិនព្រមផ្តិតមេដៃតាមសំណូមពរ របស់ឈ្មោះ [redacted] តារា ទេ ព្រោះខ្លាចឈ្មោះ[redacted]តារា ប្តឹង ទើបឈ្មោះ [redacted] តារា ក៏មិនព្រមផ្តិតមេដៃលើកំណត់ហេតុដែលចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ នោះវិញដែរ ។ ក្រោយពីភាគីទាំងពីរមិនចុះសម្រុងគ្នា ខ្លួនក៏បានណែនាំថាខ្លួនមានសមត្ថកិច្ចត្រឹមតែការសម្របសម្រួលទេ តែបើភាគីមិនពេញចិត្តប្តឹងទៅតុលាការចុះព្រោះដីទាំងអស់នេះសុទ្ធតែមានប័ណ្ណសំគាល់សិទ្ធិរៀងៗខ្លួន ។ ក្រោយមក នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ឈ្មោះ [redacted] តារា បានទូរសព្ទមកប្រាប់ខ្លួនថាឈ្មោះ [redacted] សុផាន់ណារិទ្ធ បានសង់របស់រួចរាល់ជាស្ថាពរហើយ! តើនរណាជាអ្នកអនុញ្ញាត? ខ្លួនក៏បានឆ្លើយប្រាប់វិញថាខាងសាលាក្រុងមិនបានអនុញ្ញាតឱ្យសាសង់ទេ គឺរូបគេសាងសង់ដោយខ្លួនឯង ។

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **សាលីម** បានឆ្លើយនៅចំពោះមុខតំណាងអយ្យការថា៖ កាលពីអំឡុងឆ្នាំ ២០១៥ ឈ្មោះ[redacted]សុផាន់ណារិទ្ធ បានសាងសង់របងថ្មនៅលើដី ស្ថិតនៅភូមិម៉ុងបារាំង ដែលមានព្រំប្រទល់ជាប់នឹងឈ្មោះ[redacted] តារា ហើយឈ្មោះ [redacted] តារា ក៏បានប្តឹងទៅសាលាក្រុងដើម្បីសុំទប់ស្កាត់ការសាងសង់នេះ ។ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ លោក[redacted] ភ័ព្វមីនា បានអញ្ជើញឈ្មោះ [redacted] តារា អាជ្ញាធរភូមិឃុំ ជំនាញភូមិបាល

ស្រុក និងឈ្មោះ [redacted] សុផាន់ណារិទ្ធ ចូលរួមដោះស្រាយទីតាំងកើតហេតុ នៅថ្ងៃនោះឈ្មោះ [redacted] តារា មិនបានចូលគឺរូបគេបានឱ្យឈ្មោះ ពរិន ដែលត្រូវជាកូនធម៌មកជំនួស។ ក្នុងការផ្សះផ្សារនោះឈ្មោះ [redacted] តារា បានឲ្យឈ្មោះ [redacted] សុផាន់ណារិទ្ធ សុំទោសរូបគេដោយមានធ្វើជាលិខិតលាយលក្ខអក្សរ និងប្រគល់បង្គោលរបង លួសបន្លា ប្រគល់ឲ្យគេវិញ ទើបគេយល់ព្រមឲ្យសាងសង់បន្ត។ នៅក្នុងកំណត់ហេតុនោះឈ្មោះ [redacted] តារា មិនទាន់បានផ្តិតមេដៃទេ លុះក្រោយមកទៀតឈ្មោះ [redacted] តារា ក៏បានមកជួបឈ្មោះ [redacted] សំអាត ដើម្បីមកផ្តិតមេដៃបញ្ចប់វិវាទ ប៉ុន្តែដោយមើលឃើញក្នុងកំណត់ពុំមានសរសេរដំណើរការរឿងហេតុ រូបគេបានសុំអោយសរសេរឡើងវិញ អំពីដំណើររឿងកាប់គាស់បង្គោលរបង និងបន្លាលួស ប៉ុន្តែត្រូវភាគីឈ្មោះ [redacted] សុផាន់ណារិទ្ធ មិនយល់ព្រមធ្វើឡើងវិញទេ ទើបឈ្មោះ [redacted] តារា មិនយល់ព្រមផ្តិតមេដៃលើកំណត់ហេតុចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ នោះវិញដែរ ។ ក្រោយមកទើបដឹងថាឈ្មោះ [redacted] សុផាន់ណារិទ្ធ បានសាងសង់របងរួចរាល់ជាស្ថាពរ ហើយខាងសាលាក្រុងក៏មិនបានដឹងរឿងនោះដែរ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ពិតជាមាន**ធ្វើឱ្យខូចខាតដោយចេតនា និងអំពើលួច** ប្រព្រឹត្តនៅភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤១០ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។ ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២២២៤ដ.ក.ស.៣/២០ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២០ ដដែល និងសុំឱ្យតុលាការពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យភស្តុតាង
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១. កាលពីថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ វេលាម៉ោង ០៧ និង០០ នាទី ព្រឹក នៅចំណុចភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានឈ្មោះ [redacted] សុផាន់ណារិទ្ធ ភេទប្រុស រស់នៅភូមិ-ឃុំកើតហេតុខាងលើ ពិតជាបានទៅរើកបង្គោលរបង រើបន្លាលួស កាប់គាស់ដើមចន្ទីនៅលើដី ដែលនៅជាប់នឹងព្រំដីរបស់ឈ្មោះ [redacted] តារា ភេទប្រុស ដើម្បីសាងសង់របងស៊ីម៉ង់រៀបឥដ្ឋ

ហើយត្រូវបានឈ្មោះ [redacted] តារា ប្ដឹងទប់ស្កាត់ការសាងសង់នេះ ហើយបានប្ដឹងទៅលើឈ្មោះ [redacted] សុផាន់ណារិទ្ធ ថាបានដកយកបង្គោលរបង បន្លាលួស និងគាប់ដើមចន្ទីរបស់ខ្លួន ធ្វើឱ្យខូចខាតផលប្រយោជន៍អស់ជាច្រើន ដោយសារបង្គោលរបង និងបន្លាលួសនេះបានបាត់អស់ ប្រាកដមែន ។

២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារិទ្ធិ បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដែលចម្លើយនេះគ្រាន់តែជាចម្លើយការដោះសារតែប៉ុណ្ណោះ ព្រោះថាតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស្របនឹងចម្លើយរបស់សាក្សី របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿងផងដែរ បញ្ជាក់ថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។

៣. ជនជាប់ចោទ ជានីតិជន និងជាសមត្ថជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ បានពោលគឺ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន។

៤. សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ ពីចេតនាទុច្ចរិតក្នុងការធ្វើឱ្យខូចខាតដោយចេតនានូវទ្រព្យសម្បត្តិរបស់អ្នកដទៃ និងយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនប្រាកដមែន ។

៥. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុផាន់ណារិទ្ធិ ភេទប្រុស អាយុ ៣៣ ឆ្នាំ សញ្ជាតិខ្មែរ ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា និងអំពើលួច** ប្រព្រឹត្តនៅភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤១០ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៦. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់អ្នកដទៃដែលច្បាប់ការពារ ។

៧. ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] តារា បានប្ដឹងទាមទារសំណងការខូចខាតនិងជម្ងឺចិត្តចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល គប្បីតុលាការពិនិត្យ ពិចារណា និងសម្រេចទៅតាមភាព ជាក់ស្ដែង និងសមហេតុផល ។

## ហេតុដូច្នេះសម្រេច

១. ផ្ដន្ទាទោសឈ្មោះ [redacted] **សុផាន់ណារិទ្ធ** ភេទប្រុស អាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា និងអំពើលួច** ប្រព្រឹត្តនៅភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ តាមមាត្រា ៤១០ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២. ឱ្យឈ្មោះ [redacted] **សុផាន់ណារិទ្ធ** បង់ការខូចខាតនិងជម្ងឺចិត្តចំនួន ១០.០០០.០០០ (ដប់លាន) រៀល ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] តារា ។ ច្រានចោលការទាមទារលើសពីនេះ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០២០ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សុផាន់ណារិទ្ធ** និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **តារា** នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០២០ ។

បើកសិទ្ធិប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កំពង់ឆ្នាំង, ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០២០

| | |
|---|---|
| បានឃើញ | |
| **ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជីសវនាការ** |
| [redacted] | [redacted] |